**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

# ការចាប់ផ្តើមទទួលពាក្យសុំចូលរួម
# ការប្រឡងចម្រៀងណូដូជីម៉ាន់លើកទី១០

លេខៈ 25PR-19/EoJ　　　　　　　　　　ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនថា ស្ថានទូតរួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន(CJCC) នឹងរៀបចំនូវ**ការប្រឡងចម្រៀងណូដូជីម៉ាន់លើកទី១០** (ការប្រឡងចម្រៀងភាសាជប៉ុន) នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៩ នៅ CJCC ក្នុងឱកាសពិធីបុណ្យតាណាបាតា(បុណ្យផ្កាយ)២០១៩ ផងដែរ។

ការប្រឡងចម្រៀងណូដូជីម៉ាន់(ចម្រៀងភាសាជប៉ុន) ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ក្នុងគោលបំណងលើកទឹកចិត្តអ្នកសិក្សាភាសាជប៉ុនបានអនុវត្តការបញ្ចេញសម្លេងជាភាសាជប៉ុន។ លើសពីនេះទៀត ការប្រឡងនេះក៏មានគោលបំណងពង្រឹងចំណងមិត្តភាព និងការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រជាជនជប៉ុននិងកម្ពុជាតាមរយៈចម្រៀងភាសាជប៉ុនផងដែរ។

យើងខ្ញុំសូមស្វាគមន៍អ្នកសិក្សាភាសាជប៉ុនគ្រប់កម្រិតដើម្បីចូលរួមប្រឡងចម្រៀងនេះ ក្នុងនាមជាការប្រកួតរវាងគ្រឹះស្ថានអប់រំភាសាជប៉ុន មិនមែនជាលក្ខណៈបុគ្គលទេ។ បែបបទក្នុងការដាក់ពាក្យមានភ្ជាប់ជាមួយសេចក្តីប្រកាសព័ត៌មាននេះ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២២) ឬ ផ្ញើអ៊ីម៉េលមកកាន់អាស័យដ្ឋាន៖ info.jpn@pp.mofa.go.jp ។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Email: info.jpn@pp.mofa.go.jp,*
*Official Website: www.kh.emb-japan.go.jp*

# លក្ខខណ្ឌដាក់ពាក្យប្រឡងចម្រៀងណូដូជីម៉ាន់ឆ្នាំ២០១៩

## សេចក្តីណែនាំនៃការដាក់ពាក្យប្រឡង

- ការប្រឡងលើកនេះ គឺជាការប្រកួតប្រជែងរវាងសាលា និងសាលា។ សាលារៀនភាសាជប៉ុនណាដែលមានបំណងឲ្យកូនសិស្សចូលរួមប្រឡង សូមអញ្ជើញមកដាក់ពាក្យប្រឡង។
- ចំពោះចំនួនបេក្ខជនប្រឡងចម្រៀងទោល ឬ បេក្ខជនប្រឡងជាក្រុម តាមសាលានីមួយៗ នឹងត្រូវកំណត់ចំនួនដោយយោងទៅលើ ចំនួនសាលាសរុបចុងក្រោយដែលបានដាក់ពាក្យចូលរួម និងចំនួនសិស្សនៃសាលានីមួយៗនោះផងដែរ។
- បេក្ខជនដែលចូលរួមប្រកួតត្រូវត្រៀមភ្លេងសម្រាប់ច្រៀងនៅថ្ងៃប្រឡងដោយខ្លួនឯង ហើយត្រូវផ្ញើមកកាន់ស្ថានទូតមុនថ្ងៃប្រឡង។
- ការប្រឡងចម្រៀងលើកនេះ មិនដូចការប្រឡងលើកមុនៗដែលមានខារ៉ាអូខេអាចមើលឃើញតួរអក្សរចម្រៀងទេ បេក្ខជនត្រូវទន្ទេញបទចម្រៀងឲ្យបានចាំហើយច្រៀងលើឆាកតែម្តង។
- កម្មវិធីប្រឡងចម្រៀងណូដូជីម៉ាន់

| | |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃអាទិត្យ ទី១៤ ខែកក្កដា ឆ្នាំ២០១៩ |
| ពេលវេលាហាត់សម | ០៨:០០- ០៩:០០ |
| ពេលវេលាប្រឡងចម្រៀង | ០៩:៣០ -១២:០០ |

ការប្រឡងលើកនេះ រៀបចំឡើងនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ក្នុងឱកាសពិធីបុណ្យផ្កាយ (តាណាបាតា) ថ្ងៃទី១៣ និង ១៤ ខែកក្កដា ឆ្នាំ២០១៩។

## នីតិវិធីនៃការដាក់ពាក្យ

១. ការចុះឈ្មោះចូលរួមរបស់សាលាភាសាជប៉ុននីមួយៗ (ផុតកំណត់ត្រឹមថ្ងៃសុក្រ ទី១០ ខែឧសភា ឆ្នាំ២០១៩)

ពាក្យស្នើសុំចូលរួម អាចរកបានតាមរយៈគេហទំព័រខាងក្រោម៖

https://www.kh.emb-japan.go.jp/files/000469974.pdf

២. ការប្រកាសលទ្ធផលចំនួនបេក្ខជនច្រៀងទោល ឬ ជាក្រុម នៃសាលានីមួយៗ (ថ្ងៃច័ន្ទ ទី២៧ ខែឧសភា ឆ្នាំ២០១៩)

៣. ការផ្ញើពាក្យចូលរួមប្រឡងរបស់បេក្ខជនពីសាលានីមួយៗ (ផុតកំណត់ត្រឹម ថ្ងៃសុក្រ ទី២១ ខែមិថុនា ឆ្នាំ២០១៩)

ពាក្យចូលរួមប្រឡងរបស់បេក្ខជនអាចរកបានតាមរយៈគេហទំព័រខាងក្រោម៖

https://www.kh.emb-japan.go.jp/files/000469976.pdf

៤. ការផ្ញើភ្លេងចម្រៀងពីបេក្ខជនចូលរួមប្រឡង (ផុតកំណត់ត្រឹមថ្ងៃសុក្រ ទី២៨ ខែមិថុនា ឆ្នាំ២០១៩)